ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ ៩៧ "ខ១" ក្រ៨

ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២៤៣៣

ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩

សំណុំរឿងស៊ើបសួរ

លេខ ១៥០០

ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩

សំណុំរឿងជំនុំជម្រះ

លេខ ២៣៤៨

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សានៃសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមប្រឹក្សា នៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៤៣៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ដែលមាន ៖**

១/ ជនជាប់ចោទឈ្មោះ [redacted] **គឹមសុខ** ហៅ **ពយ** ភេទប្រុស អាយុ ២៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ មានទីកន្លែងកំណើតភូ[redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលនៅបន្ទប់ជួលបឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]អិត (ស្លាប់) ម្ដាយឈ្មោះ[redacted]សិដ្ឋ (ស្លាប់) ប្រពន្ធឈ្មោះ[redacted] សាឯម កូនគ្មាន ជានីតិជន ។ (ដីកាបង្គាប់លេខ ៣៧០៥ "ខ" ដ.ឃ.ជ ចុះ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩)

២/ ជនជាប់ចោទឈ្មោះ [redacted] **ចក្រ** ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្ដាល ទីលំនៅមុនពេលឃុំស្នាក់នៅហាងខារ៉ាអូខេយីហោរុងរឿង ភូមិត្រពាំងល្វា សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានី ភ្នំពេញ ឪពុកឈ្មោះ [redacted] ង៉ោ (ស្លាប់) ម្ដាយឈ្មោះ[redacted] សារ៉ាន (ស្លាប់) នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។ (ដីកាបង្គាប់លេខ ៣៧០៣ "ខ" ដ.ឃ.ជ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩)

៣/ ជនជាប់ចោទឈ្មោះ [redacted]**អ៊ុយ** ហៅ **គ្រេន** ភេទប្រុស កើតថ្ងៃ១៤ ខែឧសភា ឆ្នាំ២០០២ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលឃុំខ្លួននៅទីលំនៅមុនពេលឃុំស្នាក់ នៅហាងខារ៉ាអូខេយីហោត្បូងពេជ្រ ភូមិត្រពាំងល្វា សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]ទ្រី (រស់) ម្ដាយឈ្មោះ [redacted] សារ៉េម (រស់) នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។ (ដីកាបង្គាប់លេខ ៣៧០៤ "ខ" ដ.ឃ.ជ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩)

ជាប់ចោទពីបទ **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវ២០០៤ ភូមិត្រពាំងល្វា២ សង្កាត់កាកាប១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌមានចែងនិងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្ដីពីត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទអ្នកស្រី [redacted] ជាមេធាវី នៃក្រុមហ៊ុនមេធាវី ម៉ារ និងសហការី មានការិយាល័យនៅអគារលេខ ២៧HJKLM អគារ East Commercial ជាន់ទី២៧ មហាវិថីព្រះនរោត្តម ភូមិ១០ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**អង្គហេតុនៃរឿងមានដូចតទៅ ÷**

កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង២២ និង១០នាទី កម្លាំងសមត្ថកិច្ចចម្រុះនៃអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ បានដាក់គោលដៅត្រួតពិនិត្យ និងឆែកឆេរ អាវុធជាតិផ្ទុះតាមបណ្តោយផ្លូវ២០០៤ ក្នុងភូមិត្រពាំងល្វា២ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ ក៏ប្រទះឃើញឈ្មោះ [redacted] គីមសុខ,ឈ្មោះ [redacted] ចក្រ និងឈ្មោះ [redacted] ម៉ុយ ជិះម៉ូតូពីរគ្រឿងម៉ាកហុងដា C125 ពណ៌ខ្មៅ គ្មានភ្លើងបំភ្លឺ និងគ្មានកញ្ចក់មកដល់គោលដៅរបស់កម្លាំងសមត្ថកិច្ចនគរបាល ។ ដោយមានការសង្ស័យសមត្ថកិច្ចបានហៅឱ្យឈប់ធ្វើការត្រួតពិនិត្យ ភ្លាមនោះជនជាប់ចោទបាននាំគ្នាផ្តួលម៉ូតូរត់គេចខ្លួន ទើបសមត្ថកិច្ចតាមចាប់ឃាត់ខ្លួនបានទាំងបីនាក់តែម្តង ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៩២៩ “ខ” ដ.ជ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **គីមសុខ** បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុខ្លួនបានចេញពីកន្លែងធ្វើការនៅផ្លូវ២០០៤ លុះមកដល់ចំណុចភូមិត្រពាំងល្វា សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ បានជួបនឹងសមត្ថកិច្ចនគរបាលកំពុងដាក់គោលដៅត្រួតពិនិត្យអាវុធជាតិផ្ទុះ និង គ្រឿងស្រវឹង ឃើញដូចនេះខ្លួនបានក៏ផ្តួលរត់គេចខ្លួន តែត្រូវកម្លាំងសមត្ថកិច្ចជិះម៉ូតូដេញតាមចាប់បានយកមកវិញ ។ ខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀនពិតប្រាកដមែន ជាមួយមិត្តភក្តិប្រាំបីនាក់ ។

- ជនជាប់ចោទឈ្មោះ [redacted] **ម៉ុយ និងឈ្មោះ** [redacted] ចក្រ បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ កាលនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ២២:១០នាទី មុនពេលកើតហេតុពួកខ្លួន ជិះម៉ូតូដោយគ្មានភ្លើងបំភ្លឺ និងគ្មានកញ្ចក់ចេញពីកន្លែងធ្វើការហាងខារ៉ាអូខេរុងរឿង ។ លុះដល់ចំណុចផ្លូវលេខ ២០០៤ ក្នុងភូមិត្រពាំងល្វា២ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ បានជួបនឹងសមត្ថកិច្ចនគរបាលកំពុងដាក់គោលដៅត្រួតពិនិត្យបានហៅពួកខ្លួនឱ្យឈប់ ដើម្បីឆែកឆេរ និងធ្វើតេស្តិ៍រកសារធាតុញៀន ឃើញវិជ្ជមានក៏ឃាត់ខ្លួន ពួកខ្លួនបញ្ជូនមកតុលាការតែម្តង ។ ពួកខ្លួនពិតប្រើប្រាស់គ្រឿងញៀនពិតប្រាកដមែន ដោយប្រើប្រាស់ជាមួយគ្នានៅហាងខារ៉ាអូខេ ។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**

ពេលសវនាការជនជាប់ចោទបានឆ្លើយថា ៖ ជនជាប់ចោទពិត ជាបានជួយគ្នាទៅវិញទៅមកឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនមែន ។ អំពើរបស់ជនជាប់ចោទបទល្មើសចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ដូចនេះតំណាងអយ្យការប្តឹងសុំឱ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

**សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

ពេលសវនាការ កូនក្តីខ្លួនបានឆ្លើយថា កូនក្តីខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀននេះប្រាកដមែន ។ ដែលអំពើនេះគឺបទល្មើសប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ ដូចនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធឱ្យជាប់ចោទស្នើសុំឱ្យក្រុមប្រឹក្សាកែប្រែបទចោទប្រកាន់ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** មកបទ**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** វិញ ។ ចំណែកកូនក្តីខ្លួនឈ្មោះ [redacted] ម៉ុយ គឺជាអនីតិជន ដូចនេះខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ផ្តល់នូវស្ថានទម្រង់ទោសដោយផ្អែកតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។



Scanned with CamScanner

-យោងតាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ១៩៣១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ឃើញថា ឈ្មោះ គង់ ម៉ុយ កើតនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០២ បើគិតត្រឹមកាលបរិច្ឆេទ នៃការប្រព្រឹត្តបទល្មើសមានអាយុត្រឹម ១៧ឆ្នាំ ប៉ុណ្ណោះ ។ ហេតុនេះ គប្បីតុលាការផ្តល់នូវស្ថានសម្រាល តាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

- វត្ថុចាប់យក ៖ ឧបករណ៍សម្រាប់ជក់មួយចំនួន ទូរស័ព្ទចំនួន ០២ គ្រឿងម៉ាក NOKIA អិនចុច ពិល ពណ៌ ខ្មៅ (មិនដំណើរការ) ។ វត្ថុចាប់យកឧបករណ៍សម្រាប់ជក់គ្រឿងញៀន ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បី រឹបអូស ។ ចំណែកវត្ថុចាប់យកផ្សេង គប្បីប្រគល់ម្ចាស់ដើមចោទ ។

**ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី**

**១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ** [redacted] ចក្រ ភេទប្រុស អាយុ២៥ឆ្នាំ និងឈ្មោះ [redacted] **គឹមសុខ ហៅ ពយ** ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល១ (មួយ)ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរធម្មតា តាមបញ្ញត្តិស្តីពីការព្យួរទោសធម្មតា នៃក្រមព្រហ្មទណ្ឌ ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលេខ ២០០៤ ភូមិត្រពាំងល្វា២ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌមានចែងនិងឱ្យតាម បញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ** [redacted] **ម៉ុយ** ភេទប្រុស អាយុ១៧ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ១០ (ដប់) ខែ ទោសសល់ពីនេះត្រូវព្យួរធម្មតា តាមបញ្ញត្តិស្តីពីការព្យួរទោសធម្មតា នៃក្រមព្រហ្មទណ្ឌពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលេខ ២០០៤ ភូមិត្រពាំងល្វា២ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌមានចែងនិងឱ្យតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣- រឹបអូសវត្ថុចាប់យកឧបករណ៍សម្រាប់ជក់មួយចំនួន បំផ្លាញចោល ។

៤- ប្រគល់វត្ថុចាប់យក ទូរស័ព្ទចំនួន ០២ គ្រឿងម៉ាក NOKIA អិនចុច ពិល ពណ៌ខ្មៅ (មិនដំណើរការ) ឱ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉ុយ ឈ្មោះ [redacted] គឹមសុខ និងឈ្មោះ [redacted] ចក្រ ។ ប្រកាសជាសាធារណៈថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រាក្រឡាបញ្ជី [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រាចៅក្រម [redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០២០

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]